# ការប្រកបរួបរួមគ្នា

សារបំផុសគំនិតដែលបងប្រុសភារីបានផ្ដល់ដល់យើង នោះគឺព្រះបន្ទូលរបស់ព្រះ។ ពិតប្រាកដណាស់ថា "យើងបានកំណត់និងដាក់ ពេលវេលាឲ្យព្រះ។ តែទ្រង់អស់កល្បជានិច្ចយើងមិនអាចធ្វើអញ្ចឹងបានទេ។" ដូច្នេះហើយនៅយប់នេះ យើងកំពុងជួបនឹងអ្វីមួយទៀត នោះគឺការប្រកបរួបរួមគ្នា។

2 បីឆ្នាំហើយ ខ្ញុំបានរង់ចាំក្រុមជំនុំមកនៅតាក់សុន ហើយវាកើតឡើងនៅថ្ងៃនេះ។ មែនហើយ យើងបានជុំគ្នាទីនេះ។ ដូច្នេះយើងអរគុណព្រះ ដែលទ្រង់អនុញ្ញាតឲ្យយើងរង់ចាំរហូតដល់យើងអាចសរសើរទ្រង់ឥឡូវនេះ។

3 ឥឡូវនេះ មានរឿងមួយដែលខ្ញុំចង់និយាយ មុននឹងយើងចាប់ផ្ដើមការរួបរួមនេះ គឺថា ខ្ញុំជឿថាយើងបានឃើញគ្រប់គ្រាន់នៅសម័យដែលយើងរស់នៅ ដែលយើងគួរតែថ្វាយ អ្វី(ទាំងអស់)នៃជីវិតយើងទៅ ព្រះ។ យើង—យើងត្រូវតែបំរើព្រះ។ ខ្ញុំជឿថាទ្រង់បានប្រទានពរដល់យើង ជាចម្លើយផ្ទាល់ក្នុងបទគម្ពីរ។ ដូចដែលបងប្រុសភារីបានចែកចាយមុននេះបន្តិច។ ថាយើង—កំពុង—នៅក្នុងសម័យកាលនេះ យើងមិនមែនជាមនុស្សខ្វាក់ទេ យើង—ឃើញថា—យើងនៅទីនេ យើង—យើងបានមកដល់ហើយ។

4 ហើយយើងក៏អាចមើលជុំវិញ ឃើញថាផ្លូវគំនិតរបស់មនុស្ស កំពុងដើរចេញពីមនុស្ស។ ដែលយើង—មិនអាចនៅយូរជាងនេះទេ យើងកំពុងស្ថិតក្នុងកាលៈទេសៈឆ្កួតមួយ ដែលពិភពលោកទាំងមូលកំពុងជួប។ ឃើញទេ? ដូច្នេះយើង—កំពុងស្ថិតនៅគ្រាចុងក្រោយ។

5 ឥឡូវនេះ ដូចជាបងប្រុសភារីបានបញ្ជាប់នៅទីនេះ ដោយឃើញថារឿងទាំងនេះគឺជារឿងពិត ឃើញថាពួកគេពិតមែន ពួកគេមិនមែនអាថ៌កំបាំងទេ។ វាមិនមែនជាអ្វីដែលយើងគ្រាន់តែស្រមើស្រមៃ។ វាគឺជាអ្វីដែលបានប្រទានមកយើងដោយព្រះបន្ទូលរបស់ព្រះ ហើយបង្ហាញជាសាធារណៈនៅចំពោះមុខយើងឲ្យយើងដឹងថាយើងនៅទីនេះ។ យើងមិន—ដឹងថាតើរយៈពេលយូរប៉ុណ្ណាទេពីព្រោះយើងត្រលប់មកមើលឡើងវិញ អ្នកឃើញទេថាពេលវេលាណាហើយ៩

ឥឡូវនេះ។ ប៉ុន្តែយើង...យើងដឹងថាយើង—នៅទីនេះ យើងដក់ពេលនេះ។ ថាតើពេលវេលារបស់ព្រះ ខ្ញុំនឹងស្រមៃមើល...

6 មានម្នាក់បានផ្ដល់ការវិភាគបន្តិច ដែលនិយាយថា បើព្រះចង់ផ្លាស់ប្ដូរគាត់តាមរយៈ...បើទ្រង់ចង់បែងចែកពេលវេលាមួយពាន់ឆ្នាំគឺ—ប្រើពេលតែមួយថ្ងៃប៉ុណ្ណោះ។ ដូច្នេះ បើបុរសម្នាក់មានអាយុចិតសិបឆ្នាំ វាគ្រាន់តែជាពីរបីនាទីនៃពេលវេលារបស់ព្រះប៉ុណ្ណោះ។ ឃើញទេ? មែនហើយ បើនិយាយទៀតថាអាយុ៤០ឆ្នាំ ដែលជាពេលដ៏ជាក់លាក់ នោះគឺគ្រាន់តែទ្រង់ព្រិចភ្នែកប៉ុណ្ណោះ។ ឃើញទេ? ឃើញទេថា វាលឿនយ៉ាងណា រឿងទាំងមូល បើសិនជាត្រូវបែងចែកពេលវេលាមែននោះ ដែលទ្រង់មិនមានពេលវេលា។ ដូច្នេះទ្រង់គង់នៅអស់កល្បជានិច្ច។

7 ខ្ញុំជឿថាសារ៉ានៅខាងក្រោយនោះ...ឬអត់ទេ ឬជាយ៉ូសែប នៅយប់ផ្សេងទៀតនោះ បាននិយាយមកកាន់ខ្ញុំនិងបងប្រុសភារី។ គាត់បាននិយាយថា "ប៉ាប៉ា តើព្រះយាងមកជារូបរាងពេលណា? តើទ្រង់យាងមកពីណា?" ឃើញទេ? "ទ្រង់ត្រូវតែមានការចាប់ផ្ដើមមែនទេ? តើទ្រង់មិនត្រូវចាប់ផ្ដើមទេឬ?"

8 ខ្ញុំនិយាយថា "អត់ទេ។ អ្វីដែលមានការចាប់ផ្ដើមត្រូវតែមានទីបញ្ចប់ ក៏ប៉ុន្តែអ្វីដែលគ្មានការចាប់ផ្ដើមនោះក៏គ្មានទីបញ្ចប់ដែរ។" ជាការពិតគាត់មានអាយុ ១០ ឆ្នាំ ដែលជាប្រភេទក្មេងនិយាយច្រើន—មាត់ច្រើន។ ឃើញទេ? ហើយតើគាត់អាចទទួលការនោះរបៀបណា ដោយដឹងថាអ្វីមួយមិនបានចាប់ផ្ដើម? មិនត្រឹមតែគាត់ទេ វាគឺសម្រាប់ខ្ញុំដែរ។ ឥឡូវនេះសូមមើលវាគ្រាន់តែជាកត្តាដ៏អស្ចារ្យមួយសម្រាប់ខ្ញុំ ថាតើវាមិនធ្លាប់ចាប់ផ្ដើមទេ។

9 ឥឡូវនេះយើងកំពុងសំលឹងមើលអ្វីមួយនៅទីនេះដែលពិតជាពិសិដ្ឋ។

10 ពីរបីថ្ងៃមុនមានគេណែនាំខ្ញុំ ឲ្យស្គាល់បុរសគ្រីស្ទានដ៏ល្អ—សុភាពរាបសារម្នាក់ ហើយគាត់យល់ថាយើងបានចូលរួមក្នុងន័យពិតប្រាកដ។ ពួកគេបានទទួលអ្វីដែលពួកគេហៅថា "ការប្រកបរួបរួមគ្នាខាងវិញ្ញាណ។" ហើយជា*ការប្រកបរួបរួមគ្នា* ដែលខ្ញុំចង់និយាយដោយត្រឹមត្រូវ ពីព្រោះ*ការប្រាស្រ័យទាក់ទង*គឺជាការ "និយាយទៅកាន់" ឃើញទេ។ ហើយបុរសនោះបានឲ្យខ្ញុំនូវបទគម្ពីរនេះ ហើយបាននិយាយថា "បងប្រុសប្រាណហាំតើបងមិនគិតទេថា..."

11 ឥឡូវនេះ ហេតុផលដែលខ្ញុំនិយាយនេះ...វាមិនអីទេ បងប្រុសភារី? [បងប្រុសភារីបានឆ្លើយថា "ប្រាកដមែន"]។ សូមមើល ហេតុផលដែលខ្ញុំកំពុងនិយាយនេះដើម្បីឲ្យអ្នកយល់ពីអ្វីដែលអ្នកកំពុងធ្វើ។ អ្នកមិន...បើអ្នកដើរចូលទៅក្នុងអ្វីដែលងងឹត អ្នកនឹងមិនដឹងថាអ្នកកំពុងធ្វើអ្វីនៅកន្លែងណានោះទេ។ អ្នកមិនអាចមានសូម្បីតែទំនុកចិត្ត បើអ្នកមិនដឹងថាអ្នកកំពុងធ្វើអ្វី។ ប៉ុន្តែអ្នកត្រូវតែយល់ពីអ្វីដែលអ្នកកំពុងធ្វើនិងហេតុអ្វីបានជាអ្នកធ្វើវា។

12 គាត់បាននិយាយថា "ឥឡូវនេះប្រសិនបើយើងទទួលយកព្រះបន្ទូលនៃព្រះ តើមិនមែនជាព្រះដែលយើងកំពុងទទួលយកទេឬអី?"

13 ខ្ញុំបានតបថា "ត្រឹមត្រូវណាស់លោក វាជាការពិត។ ប៉ុន្តែយើងបានអាននៅទីនេះ ថាវាពិតជា...ប៉ុលបានបង្រៀនពីការធ្វើពិធីលៀងព្រះអម្ចាស់។ ព្រះយេស៊ូវបានមានបន្ទូលថាៈ 'ចូរធ្វើការនេះជាសេចក្តីនឹកចាំពីខ្ញុំ។' 'ហើយនៅខណៈដែលអ្នកធ្វើវាដើម្បីរំឭកពីរខ្ញុំ នោះអ្នកបង្ហាញពីការសុគតរបស់ព្រះអម្ចាស់ រហូតដល់ទ្រង់យាងមក។'" ឃើញទេ? ឥឡូវនេះយើងកំពុងទទួលវា។

14 យើងយល់ថាលោកប៉ុល ដែលបានតែងតាំងនៅក្នុងក្រុមជំនុំ ថាជាហោរានៃគម្ពីរសញ្ញាថ្មី។ ពេត្រុស យ៉ាកុប យ៉ូហាន ពួកគេទាំងអស់បានសរសេរ (ហេតុអ្វីម៉ាថាយ ម៉ាកុស លូកា) នូវអ្វីដែលព្រះយេស៊ូវបានធ្វើ។ ប៉ុន្តែលោកប៉ូលបានដាក់វាតាមលំដាប់លំដោយ គាត់គឺ—ជាព្យាការីនៃព្រះគម្ពីរសញ្ញាថ្មី។ ដូចជាលោកម៉ូសេបានចូលទៅក្នុងទីរហោស្ថានដើម្បីទទួលការបើកសម្តែង ដើម្បីសរសេរសៀវភៅ—ប្រាំក្បាលនៃ—នៃ...សៀវភៅប្រាំដំបូងនៃព្រះគម្ពីរផងដែរ ប៉ុលក៏បានចូលទៅក្នុងទីរហោស្ថានហើយទទួលការបើកសម្តែងពីព្រះ ដើម្បីរៀបចំព្រះវិហារសញ្ញាថ្មីឲ្យនៅក្នុងលំដាប់លំដោយជាមួយសញ្ញាចាស់។

15 នៅខាងក្រោមពួកគេមានកូនចៀមសម្រាប់ថ្វាយយញ្ញបូជា។ ដែលប្រជាជនអ៊ីស្រាអែលរក្សាទុកជាការរំឭកវាត្រូវបានប្រើនៅពេលមួយដែលចេញមកពីអេហ្ស៊ីប។ ប៉ុន្តែបន្ទាប់មកពួកគេបានរក្សាទុកវាជាការរំឭកជាហូរហែរតាមរយៈយុគសម័យ។ មែនហើយ "បើសិនជាច្បាប់គឺជាស្រមោលនៃអ្វីដែលនឹងមក" អ្នកឃើញទេ។

16 ឥឡូវខ្ញុំជឿថា *ការប្រកបរួបរួម* (ដែលយើងហៅថា "ការប្រកបរួបរួម")គឺជា... "ពិធី លៀងព្រះអង្គម្ចាស់។"

17 ឥឡូវនេះយើងមានតែបីបទបញ្ញាមកពីព្រះ សម្រាប់យើងខាងផ្នែកសាច់ឈាម មួយក្នុងចំណោមពួកគេគឺ—គឺជា ពិធីលៀងព្រះអម្ចាស់។ ពិធីលាង ជើង និងបុណ្យជ្រមុជទឹក។ នោះគឺជារឿងតែបីប៉ុណ្ណោះ។ ទាំងបីនោះជាភាពឥត ខ្ចោះ ឃើញទេ។ ហើយនោះគឺជាបទបញ្ញាតែបីប៉ុណ្ណោះដែលយើងមាន។ យើង ដឹងថា នោះគឺជាបទបញ្ញាដែលបានផ្តល់ដោយសាវកប៉ូលនៅក្នុងគម្ពីរសញ្ញាថ្មី។

18 ឥឡូវនេះ បើសិនជាយើងនិយាយថា "ការរួបរួមគួរគ្រាន់តែយកព្រះបន្ទូលមក" ខ្ញុំមិនជឿថានរណាម្នាក់មានសិទ្ធទទួលយកពិធីលៀងព្រះអម្ចាស់រហូតទាល់តែ គាត់បានយក—ព្រះបន្ទូលរបស់ព្រះមកក្នុងចិត្តរបស់គាត់។ ឃើញទេ? ពីព្រោះ ខ្ញុំនឹង...ខ្ញុំនឹងអានអ្វីមួយសម្រាប់អ្នកក្នុងពេលបន្តិចទៀត ហើយអ្នកនឹងឃើញ។ ឥឡូវនេះ កត់សម្គាល់។ បន្ទាប់មកហេតុអ្វីបានជាយើង—យើងនឹង...

19 នៅលើមូលដ្ឋានដូចគ្នានេះយើងពិតជាអាចបង្ហាញអំពីភាពត្រឹមត្រូវចំពោះ កង ទ័ពសង្គ្រោះ។ ពួកគេមិនជឿលើពិធីបុណ្យជ្រមុជទឹកណាមួយឡើយដោយ និយាយថា "យើងមិនត្រូវការវាទេ។" ឥឡូវ បើយើងមិនត្រូវការពិធីបុណ្យជ្រមុជទឹក តើហេតុអ្វីបានជាយើងទទួលបុណ្យជ្រមុជទឹក? បន្ថែមទៀតថា "ទឹកមិនអាចជួយ សង្គ្រោះអ្នកទេ តែព្រះលោហិតបានសង្គ្រោះអ្នក។"

20 ខ្ញុំយល់ស្របជាមួយរឿងនោះ។ នោះជា—ជាការពិត លោហិតទ្រង់សង្គ្រោះ អ្នក មិនមែនទឹកទេ។ ប៉ុន្តែយើង*ត្រូវ*យកទឹកជាអារម្មណ៍ខាងក្រៅដែលការងារ របស់ព្រះគុណ ត្រូវបានធ្វើពីខាងក្នុង។ ឃើញទេ? ដូច្នេះយើងត្រូវតែរួបរួមគ្នា!

21 នៅពេលដែលយើងបានយកព្រះអម្ចាស់ ទុកជាយញ្ញបូជារបស់យើង ចូល មកក្នុងយើង ដូចជាកំណើតខាងវិញ្ញាណក្នុងយើង និងរាងកាយរបស់ទ្រង់ យើង រស់នៅសម្រាប់ទ្រង់ដោយព្រះបន្ទូល យើងក៏គួរតែធ្វើជានិមិត្តរូប ព្រោះវាជាបញ្ញត្តិ មួយ។ "ចូរឲ្យគ្រប់គ្នាបានប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹកក្នុងព្រះនាម ព្រះយេស៊ូវគ្រីស្ទដើម្បីលោះអំពើបាបរបស់អ្នក។"

22 ប៉ុលបាននិយាយថា "ខ្ញុំបានទទួលពីព្រះអម្ចាស់ដែលខ្ញុំបានចែកចាយដល់ អ្នករាល់គ្នា 'ថាព្រះអម្ចាស់យេស៊ូវដូចគ្នា នៅយប់ដែលទ្រង់ត្រូវគេក្បត់ បានយកនំ ប៉័ងហើយកាច់នំប៉័ងនោះចែកដល់ពួកសិស្ស ដោយ—បន្ទូលថា "ចូរយកហើយ បរិភោគចុះ ចូរធ្វើដូច្នេះដើម្បីរឭកដល់ខ្ញុំ។" រៀងរាល់ពេលដែលអ្នកយកនំប៉័ងនេះ

អ្នកបានបង្ហាញពីការសុគតរបស់ព្រះ រហូតដល់ទ្រង់យាងមក” ឥឡូវនេះយើងរកឃើញថា នៅក្នុងនោះ ពួកគេមានមនុស្សដែលចូលមក...

23 បងប្រុសដ៏មានតម្លៃនេះ ជាបងប្រុសជាទីស្រឡាញ់នេះ គាត់បានមកហើយគាត់បាននិយាយថា "ខ្ញុំមិនដែល—ខ្ញុំមិនដែលបានទទួលវាទេ បងប្រុសប្រាណហាំ ខ្ញុំមិនយល់ថាវាគឺជាអ្វីនោះទេ។” បន្ថែមទៀតថា "ខ្ញុំបានទទួលការបង្រៀនពីផ្នែកម្ខាងទៀត។”

24 ខ្ញុំបាននិយាយថា "ប៉ុន្តែសូមចាំថា យើងនឹងសារភាពថាសាវកប៉ុលបានដាក់វានៅក្នុងលំដាប់ នៅក្នុងពួកជំនុំគ្រីស្ទានដំបូង។ ពួកគេបានចេញពីព្រះវិហារ... ពីផ្ទះមួយទៅផ្ទះមួយ បានកាច់នំប៉័ងដោយភាពស្មោះត្រង់នៃបេះដូងជាដើម។ ឥឡូវនេះ” ខ្ញុំបាននិយាយថា "គាត់បានដាក់វានៅក្នុងក្រុមជំនុំ។ កាឡាទី ១:៨គាត់បាននិយាយថា 'បើសិនជាទេវតាមួយរូបពីស្ថានសួគ៌មកហើយនិយាយអ្វីផ្សេងទៀតចូរឲ្យវាត្រូវបណ្ដាសារចុះ' អ្នកឃើញទេ ឃើញទេ ឃើញទេ អ្នកដែលបានទទួលបុណ្យជ្រមុជទឹកជាថ្មីម្ដងទៀត ពីបុណ្យ ជ្រមុជរបស់លោកយ៉ូហាន ដើម្បី ទទួល បុណ្យជ្រមុជទឹក នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ។”

25 អ្នកឃើញមានរឿងបីយ៉ាងដែលយើងត្រូវតែមានរឿង—បីដែល យើងត្រូវធ្វើជានិមិត្តសញ្ញា ពិធីលៀងព្រះអម្ចាស់ ពិធីលាងជើង ពិធីជ្រមុជទឹក។ ឃើញទេ? មាន...

26 អ្នកនិយាយថា "មែនហើយ...” ឥឡូវនេះ កងទ័ពសង្គ្រោះបានយកវាចេញពីចំណុច "ចោរដែលស្លាប់ នៅពេលគាត់ស្លាប់ គាត់មិនបានទទួលបុណ្យជ្រមុជទឹកឡើយ ប៉ុន្តែព្រះយេស៊ូវទ្រង់បានមានបន្ទូលថា គាត់នឹងទៅនៅស្ថានសួគ៌។” នោះគឺជាការពិត។ នោះជាការជាក់ស្ដែង។ ប៉ុន្តែអ្នកឃើញទេគាត់—គាត់—គាត់គ្រាន់តែស្គាល់ព្រះយេស៊ូវនៅទីនោះក្នុងម៉ោងដែលគាត់ត្រូវបានស្លាប់។ ឃើញទេ? នោះគឺជាមនុស្ស—តែម្នាក់គត់ ជាឱកាសតែមួយគត់ដែលគាត់មាន។ គាត់—គឺជាចោរគាត់នៅឆ្ងាយហើយគាត់ក៏ចេញទៅ។ ហើយនៅពេលដែលគាត់បានមើលឃើញពន្លឺនោះ គាត់បានទទួលស្គាល់វា "ព្រះអម្ចាស់អើយសូមចាំខ្ញុំ!” ហើយព្រះយេស៊ូវ...នោះគឺជាការពិត។

27 ប៉ុន្តែចំពោះអ្នកហើយនិងខ្ញុំ ជាអ្នកដែលដឹងថាយើងគួរតែទទួលបុណ្យជ្រមុជទឹក តែបានបដិសេធមិនធ្វើវាវិញ នោះជារឿងអ្នកហើយនិងព្រះ។ ដូចគ្នានៅក្នុងពិធីលៀងព្រះអម្ចាស់

28 ឥឡូវនេះ នៅពេលដែលយើងទទួលពិធីលៀងព្រះអម្ចាស់នេះ វាមិនមែនគ្រាន់តែជាអ្វីដែលនិយាយថា "ខ្ញុំនឹងឡើងមកទីនេះ ហើយនឹងបរិភោគនំប៉័ងខ្លះដោយជឿ ហើយខ្ញុំក្លាយជាគ្រីស្ទាននោះឡើយ។" ប៉ុន្តែ បើអ្នកកត់សម្គាល់បន្តិចព្រះគម្ពីរបានចែងថា "អស់អ្នកដែលបរិភោគហើយផឹក បែប*មិនគួរសម*នោះនឹងមានទោសវិញ ពីព្រោះគឺជាព្រះលោហិតនិងរូបកាយរបស់ព្រះ។" ឃើញទេ? អ្នកត្រូវតែរស់ក្នុងជីវិត—ដែល...នៅចំពោះមុខមនុស្សនោះ...ហើយនៅចំពោះព្រះនិងមនុស្ស ដើម្បីបង្ហាញថាអ្នកគឺជានរណា—អ្នកត្រូវតែស្មោះត្រង់។

29 ឥឡូវនេះ បន្តិចមុននោះ។ ឥឡូវ នៅក្នុងគម្ពីរសញ្ញាចាស់នៅពេលដែលការថ្វាយយញ្ញបូជាត្រូវបានបង្កើតឡើងនូវ—លក្ខណ្ឌតិក្កៈឬពិធីបរិសុទ្ធ។ ដូចគ្នាដែរនិងពិធីជ្រមុជទឹកគឺជាពិធីបរិសុទ្ធមួយ។ ដូចគ្នានិងពិធីលាងជើងក៏ជាពិធីបរិសុទ្ធមួយ។ ហើយនិងពិធីលៀងព្រះអម្ចាស់ជាពិធីបរិសុទ្ធមួយ។ "មានពរហើយអស់អ្នកណាដែលធ្វើគ្រប់ទាំងពិធីបរិសុទ្ធរបស់ទ្រង់ ព្រមទាំងរក្សាគ្រប់ទាំងច្បាប់និងគ្រប់ទាំងបញ្ញត្តិរបស់ទ្រង់ ដើម្បីឲ្យគាត់មានសិទ្ធិចូលទៅក្នុងដើមជីវិត។"

30 ឥឡូវនេះ ចូរកត់សំគាល់នៅត្រង់ចំនុចនេះ នៅក្នុងជំពូកដំបូង នៅពេលដែលវាជាពិធីបុណ្យដំបូងនៃព្រះដើម្បីនាំយកការថ្វាយយញ្ញបូជាទៅក្នុងក្រុមជំនុំនិងវិហារនិងអាសនា ហើយថ្វាយដង្វាយរបស់អ្នក—ហើយចំពោះអំពើបាបរបស់ អ្នកគឺជាការថ្វាយយញ្ញបូជារបស់កូនចៀម។ មែនហើយ ខ្ញុំគ្រាន់តែស្រមៃមើលឃើញបងប្អូនប្រុសសាសន៍យូដាមួយចំនួនបានចុះមកតាមផ្លូវ ដោយដឹងថាគាត់មានទោសហើយគាត់ទៅអាសនា នាំយកគោឈ្មោលឬចៀមឈ្មោលឬកូនចៀមមកថ្វាយ។ គាត់បាននាំយកវាចុះមកលើផ្លូវដោយស្មោះត្រង់ ដូចដែលគាត់បានចូលមក គាត់បានដើរឡើងទៅទីនោះ ដើម្បីរក្សាបញ្ញត្តិព្រះ ដោយស្មោះតាមដែលគាត់អាចធ្វើបាន។

31 បន្ទាប់មកគាត់បានដាក់ដៃលើវាហើយសារភាពអំពើបាបរបស់គាត់ ហើយសង្ឃដាក់(អំពើបាបរបស់គាត់)លើកូនចៀម រួចកាត់បំពង់កកូនចៀម ហើយចៀមនោះ—បានស្លាប់សម្រាប់គាត់។ ដូចដែលគាត់បានដាក់ដៃនៅទីនោះ កូនចៀម

តូចខ្វាយឈាម ដៃរបស់គាត់ពោរពេញដោយឈាម ហើយឈាមនោះបានហូស្រោចពេញមកលើគាត់(កូនចៀមតូចដែលកំពុងតែដង្ហក់ហើយស្លាប់)គាត់បានដឹងថាគាត់បានធ្វើបាបហើយត្រូវតែមានអ្វីមួយត្រូវស្លាប់ជំនួសកន្លែងគាត់។ ដូច្នេះគាត់បានថ្វាយចៀមនោះ ឲ្យស្លាប់ជំនួសគាត់ស្លាប់។ មើលចុះ កូនចៀមបានស្លាប់ជំនួសកន្លែងរបស់គាត់។ បន្ទាប់មកបុរសនោះបានធ្វើវាយ៉ាងស្មោះត្រង់ចេញពីជម្រៅនៃដួងចិត្តរបស់គាត់។

32 នៅទីបំផុត ម្តងហើយម្តងទៀតម្តងហើយម្តងទៀត រហូតមកដល់ពេលនេះវាបានក្លាយជាប្រពៃណី។ បញ្ញត្តិរបស់ព្រះបានក្លាយជាប្រពៃណីដល់ប្រជាជន។ ហើយបន្ទាប់មកបានធ្លាក់មកដល់ទីនេះ "មែនហើយសូមមើលគឺ*ដូច្នេះ—និង—ដូច្នេះ* ហើយនៅថ្ងៃនេះ ប្រហែលជាខ្ញុំឡើងទៅប្រសើរជាង។ មែនហើយ ខ្ញុំនឹងថ្វាយគោមួយក្បាលប្រសើរជាង។" គាត់បានដើរចុះមកហើយនិយាយថា "មែនហើយ ព្រះអម្ចាស់អើយនេះគឺជាគោឈ្មោលរបស់ខ្ញុំ។" មើលចុះ មិនឃើញមានភាពស្មោះត្រង់អីបន្តិចសោះនៅក្នុងហ្នឹង ហើយក៏គ្មានការយល់ដឹងដែរ។

33 ឥឡូវ យើងមិនចង់ទទួលពិធីលៀងព្រះអម្ចាស់បែបហ្នឹងទេ។ នោះជារឿងដដែល ដដែលក្លាយជាតុអាហាររបស់ព្រះអម្ចាស់។

34 អេសាយ35...ទេសុំអធ្យាស្រ័យម្តងទៀត។ អេសាយជំពូក60...សូមឲ្យខ្ញុំយកត្រឡប់មកវិញ។ ខ្ញុំ—ខ្ញុំ—ខ្ញុំជឿថាវាគឺក្នុងអេសាយជំពូក២៨ ដែលជាកន្លែងដែលយើងរកឃើញនេះ។ ខ្ញុំប្រាកដណាស់ថានោះជាជំពូកត្រឹមត្រូវ។ ទ្រង់មានបន្ទូលថា "ដ្បិតត្រូវបង្រៀនច្បាប់មួយម្តងៗ ហើយនឹងឃ្លាមួយម្តងៗ មុខនេះបន្តិចមុខនោះបន្តិច។ កាន់ភ្ជាប់ទៅនឹងអ្វីដែលល្អ។ ដោយសំដីរឡប់និងភាសាដ៏ទៃអញនឹងមានបន្ទូលដល់ជនជាតិនេះ។ នេះគឺជាសេចក្តីសម្រាក។"

35 គាត់បាននិយាយថា "តុទាំងអស់របស់ព្រះអម្ចាស់បានពេញដោយកំអួត។ តើអ្នកណាដែលខ្ញុំអាចបង្រៀនគោលលទ្ធិបាន? តើខ្ញុំអាចបង្កើតឲ្យយល់បានទេ?" ឃើញទេ? ខ្ញុំគិតថានោះគឺជាបទគម្ពីរត្រឹមត្រូវគឺអេសាយ28។ "តើអ្នកណាដែលខ្ញុំអាចយល់ពីគោលលទ្ធិ?" សូមមើល "តុ" ។

36 ឥឡូវនេះ យើងបានរកឃើញនៅថ្ងៃនេះ ថារឿងដ៏អស្ចារ្យដែលយើងកំពុងធ្វើនៅរាត្រីនេះ នៅក្នុងការរំឭកនៃការសុគតរបស់ទ្រង់ និងរាងកាយរបស់ទ្រង់ ដែលយើងជឿថាយើងបរិភោគប្រចាំថ្ងៃ ឬទើបតែទទួលបានតាមរយៈការបរិភោគ ដូចជា

បងប្រុសរបស់យើងបានអធិប្បាយទៅកាន់យើង។ ទទួលយកព្រះបន្ទូលរបស់ព្រះ ដោយជឿដោយអស់ពីចិត្តរបស់យើង។ យើងឃើញវាបានលេចឡើង។ យើងឃើញវាបានប្រទានដល់យើង។ យើងមើលឃើញវាត្រឹមត្រូវ យើងមានអារម្មណ៍ថាវានៅក្នុងជីវិតរបស់យើង។ ហើយយើងត្រូវតែចូលមកដោយមនសិការជ្រាលជ្រៅនៃអ្វីដែលយើងកំពុងធ្វើ មិនដោយសារតែវាជាបទបញ្ជាប៉ុណ្ណោះទេ។

37 អ្នកចូលទៅក្នុងព្រះវិហារ ហើយជាញឹកញាប់ពួកគេបានឲ្យនំសូដាចាស់ៗ ឬប្រភេទ—អ្វីមួយដើម្បីហែកចែកគ្នា និងនំប៉័ងបំបែកវាឡើង—ឬអ្វីមួយហើយ—ហើយមនុស្សដែលជក់បារី ផឹកស្រា និងអ្វីផ្សេងទៀត ដោយសារតែពួកគេជាសមាជិកនៃ ព្រះវិហារនោះពួកគេបានមក ហើយទទួលទានអាហាររបស់ព្រះអម្ចាស់។ មែនហើយ នោះជាភាពកខ្វក់នៅចំពោះព្រះ!

38 សូម្បីតែការថ្វាយយញ្ញបូជាបាននិយាយថា "ថ្ងៃដ៏បរិសុទ្ធរបស់អ្នកនិងយញ្ញបូជារបស់អ្នកក្លាយជាក្លិនស្អុយនៅក្នុងច្រមុះរបស់ខ្ញុំ។" ប៉ុន្តែទ្រង់បានតែងតាំងពួកគេឲ្យធ្វើយញ្ញបូជានោះ។ ប៉ុន្តែរបៀបដែលពួកគេបានធ្វើវា វាក្លាយទៅជាក្លិនស្អុយមួយនៅក្នុងច្រមុះ(រន្ធច្រមុះរបស់ទ្រង់)គឺជាការបូជាដែលទ្រង់បានតែងតាំង។

39 នោះហើយជារបៀបដែលយើងទទួលយកព្រះបន្ទូលរបស់ព្រះ គ្រីស្ទានជាច្រើននាក់សព្វថ្ងៃនេះ(គ្រីស្ទានតែឈ្មោះ)។ យើងក្រោក ឈរឡើងនៅទីនេះ ហើយបង្រៀនព្រះបន្ទូលនេះ ហើយនិយាយថា "ព្រះយេស៊ូវគ្រីស្ទមិនមែនដូចគ្នាកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូតឡើយ" ហើយបង្រៀនពីការដែលទ្រង់បានសន្យានឹងយើង ថាទ្រង់នឹងលើកកិត្តិយសហើយនិយាយថា "អូ៎ គឺសម្រាប់អ្វីផ្សេងទៀត" ការថ្វាយបង្គំដ៏ឧឡារិករបស់យើងគ្រាន់តែជាក្លិនស្អុយនៅក្នុងច្រមុះរបស់ទ្រង់ប៉ុណ្ណោះ។ ទ្រង់នឹងមិនទទួលវាដោយឥតប្រយោជន៍ឡើយ។ នោះហើយជាមូលហេតុដោយទម្លាប់ប្រពៃណីរបស់យើង!

40 អ្នកមិនគួរយកពិធីលៀងរបស់ព្រះអម្ចាស់ជាប្រពៃណីទេ។ អ្នកធ្វើវាព្រោះជាសេចក្ដីស្រឡាញ់របស់ព្រះនៅក្នុងដួងចិត្តអ្នក ក្នុងការរក្សាបទបញ្ញត្តិរបស់ព្រះ។ ហ្នឹងហើយ ជាអ្វីដែលអ្នកគួរទទួល។

41 ដូច្នេះបើសិនជាអ្នកមិនទទួលដោយស្មោះត្រង់នោះទេគ្រាន់តែធ្វើជាប្រពៃណីមួយ "មែនហើយ ព្រះវិហាររបស់យើងចំណាំថាពិធីលៀងព្រះអម្ចាស់ជារៀងរាល់ថ្ងៃ

អាទិត្យ ឬម្ដងក្នុងមួយខែឬពីរដងក្នុងមួយឆ្នាំ" ហើយអ្នកឡើងទៅនិយាយថា "ហ្នឹងហើយ ដល់វេនខ្ញុំហើយ" ហើយ—បន្ទាប់មកទទួលយកពិធីលៀងព្រះអម្ចាស់នោះហេតុអ្វី? វាជាក្លិនស្អុយដល់ព្រះ! សូមមើលនោះគឺជាប្រពៃណី។

42 ដូចជាអ្វីផ្សេងទៀត អ្នក—អ្នកក៏ត្រូវស្មោះត្រង់។ ព្រះចង់បានជម្រៅនៃដួងចិត្តរបស់អ្នក។ អ្នកចាំបានថាព្រះដែលបាននាំអ្នកមកផែនដីនេះ គឺជាអ្នកដែលអ្នកកំពុងបម្រើ។ ឃើញទេ?

43 អ្នកកំពុងធ្វើការនេះដោយព្រោះទ្រង់មានបន្ទូលដូច្នេះ ពីព្រោះវាជាសេចក្ដីបង្គាប់របស់ទ្រង់។ បន្ទាប់មកយើងចង់មានភាពស្មោះត្រង់ ដោយដឹងថាដោយព្រះគុណរបស់ព្រះដែលយើងបានសង្គ្រោះ។ ហើយយើង—យើងស្រលាញ់ទ្រង់ ហើយយើងដឹងពីវត្តមានរបស់ទ្រង់ ហើយយើង—យើងឃើញវាបានផ្លាស់ប្រែនៅក្នុងជីវិត។ អ្វីៗ—ទាំងមូលរបស់យើងត្រូវបានផ្លាស់ប្រែ។ យើង—យើង—យើងជាមនុស្សខុសពីមុន។ យើងមិនរស់នៅដូចដែលយើងធ្លាប់ធ្វើនោះទេ យើងមិនគិតដូចដែលយើងធ្លាប់គិតនោះទេ។

44 ដូចនៅក្នុងសៀវភៅនៅទីនេះ និងចំណុចនៅទីនោះ ដែលយើងបាននិយាយសៀវភៅពីរ—រួមមកតែមួយ ជាសៀវភៅនៃជីវិត។ សៀវភៅដំបូងនៃជីវិតបានលេចឡើង គឺនៅពេលដែលអ្នកបានកើតមកនោះ គឺជាកំណើតធម្មជាតិរបស់អ្នក។ ឃើញទេ? ប៉ុន្តែបន្ទាប់មកមានពេលមួយត្រឡប់មកវិញ ចុះនៅទីនោះមានគ្រាប់ធញ្ញជាតិតូចមួយនៃជីវិតដូចដែលខ្ញុំបានពន្យល់ដល់ប្អូនស្រីវ័យក្មេងមួយចំនួននៅផ្ទះនៅរសៀលនេះ។ សូមមើលមានគ្រាប់ពូជតូចនៃជីវិតដាក់នៅទីនោះដែលអ្នកឆ្ងល់ថា "តើវាមកពីណា? តើ—តើអ្វីចម្លែកម្លេះ?"

45 ខ្ញុំកំពុងតែនិយាយការនេះដោយខ្លួនឯងដូចជាអ្នកនិយាយថា "វិលៀមប្រាណហាំ សែសិបឆ្នាំមុននិងលោកវិលៀមប្រាណហាំយប់នេះមិនដូចគ្នាទេ។" បើមានអ្នកខ្លះខាងក្រោយនោះនិយាយថា "លោកវិលៀមប្រាណហាំគាត់មានឋានៈខ្ពង់ខ្ពស់ណាស់" ពីព្រោះខ្ញុំបានកើតពីលោក ឆាលេស និង អ៊ីឡាប្រាណហាំ។ នៅក្នុងធម្មជាតិរបស់ពួកគេខ្ញុំជាមនុស្សមានបាប ខ្ញុំបានចូលមកលោកិយជាអ្នកកុហក ហើយទម្លាប់ទាំងអស់នៃលោកិយបានដាក់នៅក្នុងខ្ញុំ។ ប៉ុន្តែចុះនៅទីនោះផងដែរ គឺមានធម្មជាតិមួយផ្សេងទៀត ឃើញទេ វាបានតំរូវទុកជាមុន គឺនៅទីនោះដោយសារព្រះ។ នៅក្នុងរូបកាយតែមួយនេះ ឃើញទេ លក្ខណៈពីរនៅទីនោះ។

46 មែនហើយខ្ញុំគ្រាន់តែបំពេញការងារតែមួយប៉ុណ្ណោះ។ ពេលចាប់ផ្ដើមជាទារក "កូនង៉ា" ទីមួយអ្នកដឹងទេ ខ្ញុំក្លាយជាមនុស្សកុហក ក្លាយជាអ្វីទាំងអស់ដែលជាមនុស្សមានបាបបានធ្វើ ពីព្រោះខ្ញុំបានកើតមកបៀបនោះ។ ប៉ុន្តែចុះនៅទីនោះមានពន្លកនៃជីវិតគ្រប់ពេលវេលា។

47 ខ្ញុំចាំបានថាកាលខ្ញុំនៅក្មេង...(ខ្ញុំសង្ឃឹមថាមិនអាចកាន់អ្នកយូរបានទេ។ ប៉ុន្តែស្គាល់...) អង្គុយនៅខាងក្រៅ...លើ—លើច្រាំងទន្លេហើយខ្ញុំអង្គុយនៅទីនោះហើយមើលជុំវិញនៅពេលយប់។ ប៉ុបនិងម៉ាក់ពួកគេបានទៅកន្លែងសម្រាករបស់ពួកគេ។ ហើយនៅថ្ងៃទាំងនោះពួកគេគឺជាមនុស្សមានបាប ហើយគ្មានពួកគ្រីស្ទាននៅក្នុងផ្ទះរបស់យើងទាល់តែសោះ។ ហើយអូខ្ញុំអើយ ផឹកស៊ីជប់លៀង។ វាធ្វើឲ្យខ្ញុំឈឺ ខ្ញុំនឹងយកចង្កៀងគោមរបស់ខ្ញុំ ហើយបណ្ដើរឆ្កែរបស់ខ្ញុំទៅព្រៃដើម្បីសម្រាកពេញមួយយប់។ នៅក្នុងរដូវរងារ ខ្ញុំដើរបរបាញ់រហូតដល់ពិធីជប់លៀងនោះចប់ប្រហែលទាបភ្លឺ។ ត្រលប់មកផ្ទះវិញ ពិធីជប់លៀងត្រូវចប់ ខ្ញុំឡើងលើដំបូលហើយដេកលក់ រង់ចាំសម្រាកពេលថ្ងៃ។

48 បន្ទាប់មកខ្ញុំគិតពីពេលវេលានោះបន្ទាប់ទៀត ត្រូវចេញពីទីនោះនៅក្នុងរដូវក្ដៅយកដំបងរបស់ខ្ញុំនិងដាក់វាទុកបាំងខ្យល់ ការពារបើសិនជាមានវាភ្លៀង ដាក់ដាំបង្គោលជាប់ក្នុងដី នេសាទត្រី។ ឆ្កែចាស់របស់ខ្ញុំនៅទីនោះ។ ខ្ញុំនិយាយថា "លូគីមកណេះ។ អ្នកដឹងទេ កាលពីរដូវរងារមុន ខ្ញុំបានបោះជំរុំនៅទីនេះមួយយប់ ខ្ញុំបានដុតភ្លើងនៅទីនេះ នៅពេលខ្ញុំកំពុងរង់ចាំឆ្កែចាស់របស់ខ្ញុំនៅដើមឈើនេះ។ ហើយខ្ញុំមានភ្លើងនៅទីនេះ។ វាត្រូវបានកកជម្រៅប្រាំអ៊ីញទៅក្នុងដី។ ប៉ុន្តែមានផ្កាតូចៗ តើឯងមកពីណា?" ឃើញទេ? "មែនហើយ តើឯងមកពីណា? តើអ្នកណាចេញមកទីនេះហើយដាំឯង? ហើយតើពួកគេបាននាំអ្នកចេញពីកន្លែងណា?ឬ—ឬចុះវាវិញ តើឯងមកពីណា?" ឃើញទេ? ផ្កាតូចៗនោះ ខ្ញុំចង់និយាយថា "ហេតុអ្វី អ្វីទាំងអស់ត្រូវកក ហើយខ្ញុំបានបង្កាត់ភ្លើងនៅលើកំពូលនៅទីនេះ។ ក្រៅពីធាតុត្រជាក់មានធាតុកំដៅមួយដាក់នៅលើកំណាត់ឈើចាស់មួយដែលខ្ញុំបានដុតឯង។ តែមើលឯងកំពុងរស់នៅ។ តើឯងមកពីណា?"

49 តើវាគឺជាអ្វីទៅ? គឺជាវីលៀមប្រាណហាំមួយទៀត។ ឃើញទេ? ចំណុចតូចមួយនៃជីវិតអស់កល្បជានិច្ចចុះនៅទីនោះ ពី—ពី—ពីហៀរនៃព្រះព្រះបន្ទូលនៃ

ព្រះ ដែលត្រូវបានដាក់នៅទីនោះ។ អ្នករាល់គ្នាម្នាក់ៗអាចគិតពីរឿងស្រដៀងគ្នា។ ឃើញទេ វាបានកើតឡើង។

50 បន្ទាប់មកមើលទៅដើមឈើ ហើយខ្ញុំគិតថា "ស្លឹកឈើនោះខ្ញុំបានឃើញឯងជ្រុះកាលពីឆ្នាំមុនហើយហេតុអ្វីបានជាឯងត្រឡប់មកវិញម្តងទៀត? តើឯងមកពីណា? អ្វីដែលនាំឯងមកទីនេះ?" សូមមើលវាគឺជាជីវិតអស់កល្បជានិច្ចដែលធ្វើការនៅក្នុងរាងកាយ។

51 ឥឡូវនេះ នៅថ្ងៃមួយខ្ញុំបានដើរទៅលើ មានឮសម្លេងនិយាយថា "កុំជក់បារីឬផឹកស្រាជាដើម"។ ហើយប្អូនៗ វ័យក្មេងទាំងអស់គ្នាមានវ័យកាន់តែចាស់។ ឃើញទេ មានអ្វីកំពុងផ្លាស់ប្តូរ។

52 ប៉ុន្តែនៅពេលដែលខ្ញុំបានក្រឡេកមើលទៅ ហើយខ្ញុំបាននិយាយថា "ខ្ញុំមិនមែនជាកូនរបស់លោក ឆាលេស និង អេឡាប្រាណហាំទេ។ មានអ្វីមួយកំពុងហៅ។" ដូចជាកូនឥន្ទ្រីរបស់ខ្ញុំដែរ "ខ្ញុំមិនមែនជាមាន់ទេ។ មានអ្វីមួយនៅត្រង់កន្លែងនោះ។ ឱព្រះយេហូវ៉ាដ៏អស្ចារ្យអើយ សូមអញ្ជើញបើកទ្វារឡើង! ខ្ញុំចង់ត្រលប់មកផ្ទះវិញ។ មានអ្វីមួយនៅក្នុងខ្ញុំបានហៅ។"

53 បន្ទាប់មកខ្ញុំបានកើតជាថ្មី។ ជីវិតដ៏តូចនោះត្រូវបានដាក់នៅទីនោះ ទឹកនៃជីវិតត្រូវបានចាក់មកលើវា បន្ទាប់មកវាចាប់ផ្តើមរីកលូតលាស់។ ឥឡូវនេះជីវិតចាស់ត្រូវបានអត់ទោស ហើយដាក់នៅក្នុងសមុទ្រនៃរបស់ព្រះ ដែលមិនចងចាំ ប្រឆាំងនឹងខ្ញុំទៀតឡើយ។ ឃើញទេ? ឥឡូវនេះយើងឈរបានរាប់ជាសុចរិត(ដូចជាយើងមិនធ្លាប់ធ្វើបាប)នៅក្នុងវត្តមាននៃព្រះ។

54 នៅពេលដែលយើងចូលមកក្នុងតុរបស់ព្រះអម្ចាស់ យើងត្រូវតែចូលមកដោយសេចក្តីគោរពស្រឡាញ់ "មើលទៅកន្លែងដែលយើងបានធ្វើ ប្រសិនបើវាមិនមែនជាទ្រង់។" ឃើញទេ? រកមើលកន្លែងដែលវានឹង...

55 ហេតុនេះហើយ ខ្ញុំគិតថាសាវកប៉ុលបាននិយាយថា "ដូច្នេះនៅពេលដែលអ្នករាល់គ្នាបរិភោគចូររង់ចាំអ្នកផ្សេងទៀតផង។" នោះគឺជាពាក្យផ្សេងទៀតគ្រាន់តែរង់ចាំពីរបីនាទី សូមអធិស្ឋាន ពិនិត្យខ្លួនឯង។ ហើយបើសិនជាអ្នកដឹងថាបងប្រុសម្នាក់នៅទីនោះ គឺប្រហែលជាធ្វើអ្វីមួយដែលខុសឬអ្វីមួយ ហើយអ្នកក៏បានអធិស្ឋានឲ្យគាត់។ ឃើញទេ? សូមមើល "រង់ចាំមួយភ្លែត" រង់ចាំមួយភ្លែត

អធិស្ឋាន។ ប្រសិនបើមានអារម្មណ៍ណាមួយរវាងអ្នកឬអ្វីមួយ កុំ—កុំទទួលវា—កុំធ្វើវា ទៅកែប្រែឲ្យបានត្រឹមត្រូវសិន។ ឃើញទេ? ចូរតម្រង់សិន ពីព្រោះយើងចង់មកទីនេះ ដោយបរិសុទ្ធតាមដែលយើងអាចធ្វើបាន ហើយគំនិតរបស់យើងមួយផ្សេងទៀតទៅចំពោះព្រះ និងគ្នាទៅវិញទៅមក ហើយបន្ទាប់មកយើងមកនៅក្នុងការប្រកបនៅជុំវិញតុរបស់ព្រះអម្ចាស់។ ឃើញទេ?

56 ហើយយើងធ្វើដូច្នេះដោយព្រោះយើងកំពុងតែអរគុណដល់ទ្រង់ ហើយក្នុងចំណោមមនុស្សផ្សេងទៀត។ បរិភោគនំប៉័ងរវាងគ្នាទៅវិញទៅមក ផឹកស្រារវាងគ្នាទៅវិញទៅមក ដូចជាព្រះលោហិតរបស់ទ្រង់និងសាច់ឈាមរបស់ទ្រង់។

57 "បើអ្នកមិនបរិភោគសាច់នៃកូនមនុស្សហើយផឹកពីលោហិតរបស់ទ្រង់ទេ នោះអ្នកគ្មានជីវិតនៅក្នុងខ្លួនឡើយ។" អ្នកឃើញទេ? នោះគឺជាអ្វីដែលព្រះគម្ពីរបានចែង។ លើកលែងតែអ្នកធ្វើវា នោះទើបមានជីវិត។ អ្នកឃើញទេ? អ្នកទោះតិចឬច្រើន ត្រូវបង្ហាញថាអ្នកខ្មាស់អៀនក្នុងការបង្ហាញអត្តសញ្ញាណខ្លួនឯងថាជាគ្រីស្ទាន ដោយសារតែជីវិតដែលអ្នករស់នៅ។ ហើយបន្ទាប់មកនេះគឺជាការបង្ហាញ។ បន្ទាប់មកប្រសិនបើអ្នកមិនធ្វើវាអ្នកគ្មានជីវិតទេ។ បើអ្នកធ្វើវាដោយគ្មានតម្លៃនោះអ្នកមានទោសពីរូបអង្គព្រះអម្ចាស់។

58 ដូចគ្នាដែរនៅក្នុងពិធីបុណ្យជ្រមុជទឹក។ បើយើងនិយាយថា "យើងជឿលើព្រះយេស៊ូវគ្រីស្ទទ្រង់បានសង្គ្រោះយើងពីអំពើបាប ហើយយើងទទួលបុណ្យជ្រមុជទឹកនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ" ហេតុអ្វីយើងនាំ—យើងនាំភាពអាម៉ាស់មកកាន់ទ្រង់ យើងធ្វើអ្វីដែលខុសហើយយើង—យើងត្រូវតែសងចំពោះការនោះ។ ហើយរឿងមួយទៀត នៅពេលដែលយើងធ្វើដូច្នោះ យើងកំពុងតែព្យាយាមនិយាយរឿងមួយ ហើយធ្វើកិច្ចការមួយទៀត។

59 នោះគឺជាបញ្ហារបស់ពួកយើងសព្វថ្ងៃនេះ។ អ្វីដែលខ្ញុំគិត...ខ្ញុំកំពុងនិយាយថា "យើង" ខ្ញុំហើយនិងក្រុមជំនុំរបស់ព្រះអម្ចាស់ដែលបានអនុញ្ញាតឲ្យខ្ញុំនិយាយទៅកាន់នៅក្នុងម៉ោងចុងក្រោយនេះ ដែលយើងជឿថាយើងនៅក្នុងសម័យចុងក្រោយ។ យើងជឿថាព្រះបានប្រទានសារមួយដល់យើង។ វាត្រូវបានតែងតាំងឡើងដោយព្រះ វាត្រូវបានបង្ហាញឲ្យឃើញពីព្រះ វាត្រូវបានបង្ហាញពីព្រះ។ ឥឡូវនេះយើងត្រូវតែមករកទ្រង់ដោយសេចក្ដីគោរពនិងដោយសេចក្ដីស្រឡាញ់ ដោយមានភាពបរិសុទ្ធនៃចិត្តគំនិតនិងព្រលឹង។

60 លោកអ្នកដឹងទេ ថាគ្រាចុងក្រោយនឹងកើតឡើង នៅពេលដែលយើងនៅជាមួយគ្នានឹងជា...ព្រះវិញ្ញាណបរិសុទ្ធនឹងនិយាយចេញ ដូចជាបានធ្វើនៅក្នុងអាណានាសនិងសាភីរ៉ា។ ចាំបានទេ ឃើញទេ ថាម៉ោងនោះកំពុងមកដល់។ ឃើញទេ? ហើយយើង...ឥឡូវទើបអ្នកចាំបាន សូមមើល ថាព្រះនឹងរស់នៅក្នុងចំណោមរាស្ត្រទ្រង់។ នោះជាអ្វីដែលទ្រង់ចង់ធ្វើឥឡូវនេះ។

61 យើងអាចទទួលសារ ដូចដែលបាននិយាយថា...បើខ្ញុំជាយុវវ័យកំពុងស្វែងរក—ប្រពន្ធ ហើយខ្ញុំអាចរកប្រពន្ធបាន ខ្ញុំនឹងនិយាយថា "នាងគឺល្អឥតខ្ចោះ។ នាងជាគ្រីស្ទាន។ នាងគឺជាស្ត្រី។ នាងល្អទាំងអស់ ខ្ញុំមានទំនុកចិត្ត។" មិនថាមានទំនុកចិត្តប៉ុណ្ណានោះទេ នាងស្អាតយ៉ាងណា ខ្ញុំត្រូវតែទទួលនាង នាងត្រូវតែទទួលខ្ញុំ។ សូមមើល នៅលើពាក្យសច្ចានេះ។

62 មែនហើយ វាគឺជារឿងដដែលដែលយើងរកឃើញព្រះបន្ទូល។ យើងឃើញវាជាការត្រឹមត្រូវ។ យើងឃើញព្រះជាម្ចាស់បញ្ជាក់ថាវាជាការត្រឹមត្រូវ។ វាត្រឹមត្រូវណាស់។ ពីមួយឆ្នាំទៅមួយឆ្នាំពីមួយឆ្នាំទៅមួយឆ្នាំវានៅតែបន្តត្រឹមត្រូវជានិច្ច។ អ្វីគ្រប់យ៉ាងដែលបានចែង នោះកើតឡើងដូចទ្រង់បានមានបន្ទូល។ ឥឡូវនេះ យើងដឹងថាវាត្រឹមត្រូវ ប៉ុន្តែ សូមមើល កុំធ្វើវាពីទស្សនវិជ្ជាបញ្ញា។ បើសិនជាអ្នកធ្វើបែបនោះ អ្នកនឹងទទួលសាសនាទីពីរ។ ឃើញទេ? យើងមិនចង់បានសាសនាទីពីរទេ ជាអ្វីមួយដែលនរណាម្នាក់ផ្សេងទៀតបានជួបប្រទះ ហើយយើងកំពុងរស់នៅ—ដោយគ្មានទីបន្ទាល់។

63 ដូចដែលខ្ញុំបានជឿថាវាគឺជាព្រះយេស៊ូវមានបន្ទូលទៅកាន់លោកពីឡាត់អ្វីមួយ ជាពាក្យដែលខ្ញុំបានគិត ហើយទ្រង់បានមានបន្ទូលមុននេះបន្តិចថា "តើនរណាបានប្រាប់អ្នក?" ឬ "តើវាបានបើកសម្តែងដល់អ្នកឬ? តើអ្នកដឹងពីរឿងទាំងនេះដោយរបៀបណា?" ជាពាក្យផ្សេងទៀត។ ខ្ញុំមិនដឹងថាពាក្យនោះគឺជាអ្វីឥឡូវនេះទេ វាជាពេលយូរណាស់ចាប់តាំងពីខ្ញុំបានអានវាប៉ុន្តែ "តើអ្នកបានដឹងពីរបៀបនេះយ៉ាងម៉េច? តើអ្វីទៅ? តើធ្វើដូចម្តេច? តើនរណាជាអ្នកបើកសម្តែងការនេះដល់អ្នក?" អំពីទ្រង់ជាព្រះរាជបុត្រានៃព្រះ។ "តើអ្នកណាដែលបានបង្ហាញវាដល់អ្នក? តើមានមនុស្សខ្លះបានប្រាប់អ្នកឬ? ឬ" ដូចជាព្រះយេស៊ូវទ្រង់មានបន្ទូលថា "តើវាជាព្រះវរបិតារបស់ខ្ញុំនៅស្ថានសួគ៌ ដែលបានបើកសម្តែងដល់អ្នក

ឬ?″ ឃើញទេ? ឃើញទេ? ‶តើអ្នកបានរៀនវាដោយរបៀបណា ហើយវាគឺជាការបើកសម្តែងដ៏ល្អឥតខ្ចោះពីព្រះ?″

64 តើពិធីលៀងព្រះអម្ចាស់គឺជាអ្វីមួយដែលខ្ញុំគ្រាន់តែឡើងទៅធ្វើវា ជាបទបញ្ញា ហើយនិយាយថា ‶មែនហើយ អ្នកផ្សេងទៀតយកវាទៅ ខ្ញុំក៏ធ្វើវាដែរ″? វាជាការបើកសម្តែងមួយដែលខ្ញុំជាផ្នែកមួយនៃទ្រង់ហើយខ្ញុំជាផ្នែកមួយនៃអ្នក ហើយខ្ញុំស្រឡាញ់អ្នក ហើយខ្ញុំស្រឡាញ់ទ្រង់ ហើយយើងកំពុងធ្វើវាជាមួយគ្នាជានិមិត្តសញ្ញានៃសេចក្តីស្រឡាញ់របស់យើងចំពោះព្រះ ហើយនិងសេចក្តីស្រឡាញ់និងការប្រកបគ្នាទៅវិញទៅមក។

65 ឥឡូវនេះខ្ញុំចង់អានខខ្លះពីព្រះគម្ពីរ។ ហើយបន្ទាប់មកខ្ញុំ…តើកន្លែងណា… មិនថាផ្លូវណាមួយដែលបងប្រុសភារីប្រាថ្នានៅថ្ងៃនេះ។ ខ្ញុំសង្ឃឹមថាអ្នកនឹងអានវាជាមួយខ្ញុំ បើអ្នកមានព្រះគម្ពីររបស់អ្នក។ កូរិនថូសទី 1ជំពូកទី 11 ហើយចាប់ផ្តើមដោយខ 23។

66 ហើយបន្ទាប់មកផងដែរ នៅក្នុងរោងឧបោសថយើង តែងតែធ្វើការនេះនិងការលាងជើងជានិច្ចពីព្រោះពួកគេបានពួតដៃបំរើជាមួយគ្នា។ ខ្ញុំជឿថាបងប្រុសបានប្រកាសហើយ ‶យប់ថ្ងៃពុធ″ ដោយសារតែហ្វូងមនុស្សច្រើនពេក យើងគ្មានបន្ទប់ដើម្បី…ឲ្យមនុស្សចូលក្នុងការលាងជើងពួកគេ យើងនឹងធ្វើវានៅយប់ថ្ងៃ—ពុធនេះ។

67 ឥឡូវនេះខ 23នៃជំពូកទី 11 នៃកូរិនថូសទី 1 ចូរស្តាប់នៅប៉ុលឥឡូវនេះ។ សូមចាំហើយចងចាំនៅក្នុងចិត្តកាឡាទី 1:8 ‶ប៉ុន្តែបើយើងខ្ញុំឬទេវតាពីស្ថានសួគ៌នឹងប្រាប់ដំណឹងណាដល់អ្នករាល់គ្នាខុសពីដំណឹងល្អ″ (ខុសពីដំណឹងល្អដែលយើងខ្ញុំបានប្រាប់ហើយ) ‶នោះឲ្យគេត្រូវបណ្តាសារចុះ។″ ឃើញទេ?

> *ដ្បិតឯសេចក្តីដែលខ្ញុំបានបង្រៀនដល់អ្នករាល់គ្នា នោះខ្ញុំបានទទួលពីព្រះអម្ចាស់មក គឺថានៅពេលយប់ដែលព្រះអម្ចាស់យេស៊ូវត្រូវគេបញ្ជូន នោះទ្រង់បានយកនំបុ័ង*
>
> *លុះទ្រង់បានអរព្រះគុណរួចហើយ ក៏កាច់នំបុ័ងដោយមានព្រះបន្ទូលថា ចូរយកពិសាចុះ នេះជារូបកាយខ្ញុំ ដែលត្រូវកាច់សំរាប់អ្នករាល់គ្នា ចូរធ្វើកិច្ចនេះ ទុកជាសេចក្តីរំឭកពីខ្ញុំចុះ*

68 ឥឡូវនេះសូមអនុញ្ញាតឲ្យខ្ញុំឈប់នៅទីនេះដើម្បីនិយាយប៉ុន្តែការទទួលយករូបកាយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅក្នុងការប្រកបរួបរួមនេះ មិនមែនមានន័យថារួបរួម*សំដៅត្រង់*ទៅរូបកាយរបស់ព្រះគ្រីស្ទទេ។ នោះគឺជាកាតូលិក។ ខ្ញុំមិនជឿថានោះជាការពិតទេ។ ខ្ញុំជឿថាវាគ្រាន់តែជាពិធីមួយដែលព្រះបានបង្កើតជាមួយយើងតែប៉ុណ្ណោះ វាមិនមែនជារូបកាយពិតទេ។ វាជា...ឥឡូវនេះវាពិតជាដុំតូចមួយនៃនំប៉័ង។ វាគ្រាន់តែជាពិធីបរិសុទ្ធមួយប៉ុណ្ណោះ។

69 ដូចគ្នាដែលខ្ញុំជឿពីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូវគ្រីស្ទ(នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ)ទៅក្នុងទឹកបានអត់ទោសអំពើបាបរបស់អ្នកដែរ។ ខ្ញុំមិនជឿថាអ្នក...ខ្ញុំជឿថាអ្នកអាចទទួលបុណ្យជ្រមុជទឹកពេញមួយថ្ងៃ...ឥឡូវនេះខ្ញុំដឹងថាប្រហែលជាមានមនុស្សអង្គុយនៅទីនេះ ដែលមកពីក្រុមជំនុំពួកសាវកឬពួកជំនុំ ពេនទេកុស ដែលពួកគេបានបង្រៀន។ ប៉ុន្តែអ្នកឃើញទេខ្ញុំ—មិនជឿថាទឹកអាចអត់ទោសបាបបានទេ។ ឬបើអញ្ចឹងមែន នោះព្រះយេស៊ូវបានសុគតគឺឥតប្រយោជន៍ទេ។ ឃើញទេ? ខ្ញុំជឿថាវាគ្រាន់តែជាពិធីបរិសុទ្ធរបស់ព្រះប៉ុណ្ណោះ ឃើញទេ ដើម្បីបង្ហាញថាអ្នកត្រូវបានអត់ទោស។ ប៉ុន្តែដែលទទួលបុណ្យជ្រមុជទឹកសម្រាប់ការកើតជាថ្មីទេ—ខ្ញុំ—មិនជឿទេ។ ខ្ញុំមិនជឿថាទឹកអាចអត់ទោសបាបបានទេ។

70 ខ្ញុំក៏មិនជឿថានំប៉័ងនិងស្រានេះមានអ្វីដែលត្រូវធ្វើជាមួយអ្នកដែរ មានតែការរក្សាពិធីបរិសុទ្ធដែលព្រះបានតែងតាំងសម្រាប់យើងឲ្យធ្វើប៉ុណ្ណោះ។ ឃើញទេ? ត្រឹមត្រូវ។ ខ្ញុំជឿថាការជ្រមុជទឹកគឺជារឿងដូចគ្នា។ ខ្ញុំជឿថាវាគួរឲ្យទាក់ទាញអារម្មណ៍ដល់យើងក្នុងការធ្វើវា ដែលទ្រង់បានធ្វើវាសម្រាប់គំរូដល់យើង។ ហើយទ្រង់បានធ្វើរឿងនេះសម្រាប់ជាគំរូដល់យើង។ ហើយទ្រង់លាងជើងសំរាប់ជាគំរូដល់យើង។

71 ឥឡូវនេះ "លុះក្រោយដែលបានបរិភោគរួចហើយ" ខ 25

*លុះក្រោយដែលបានបរិភោគរួចហើយ នោះទ្រង់ក៏យកពែងបែបដូច្នោះដែរ ដោយព្រះបន្ទូលថា ពែងនេះជាសញ្ញាថ្មី ដោយនូវឈាមខ្ញុំ ចូរធ្វើដូច្នេះរាល់វេលាណាដែលផឹក ទុកជាសេចក្តីរំឭកដល់ខ្ញុំ*

*ដ្បិតរាល់វេលាណា*...(ចង់ចាំឥឡូវ)...*ដែលអ្នករាល់គ្នាបរិភោគនំប៉័ងនេះហើយផឹកពីពែងនេះ នោះឈ្មោះថាសំដែងពីសេចក្តីសុគត*

*របស់ផងព្រះអម្ចាស់ ដរាបដល់ទ្រង់យាងមក។* (ដល់ពេលណា?) "រហូតដល់ទ្រង់យាងមក!" ឃើញទេ? ឃើញទេ?

*បានជាអ្នកណាដែលបរិភោគនំបុ័ងនេះ ឬផឹកពីពែងនៃព្រះអម្ចាស់ បែបមិនគួរសម នោះនឹងមានទោសចំពោះរូបអង្គ ហើយនិងព្រះលោហិតនៃព្រះអម្ចាស់។*

72 សូមឲ្យខ្ញុំឈប់នៅមួយនាទីសិន។ មូលហេតុដែលទ្រង់មានបន្ទូលដូច្នេះ អ្នកកត់សម្គាល់ឃើញនៅខមួយផ្សេងទៀតទីនេះ នៅជំពូកមួយទៀត ដែលទ្រង់មានថា "ខ្ញុំយល់ នៅពេលដែលអ្នក—មកជួបជុំគ្នាអ្នកកំពុងតែបរិភោគ ទាល់តែស្រវឹងនៅតុរបស់ព្រះអម្ចាស់។" ពួកគេយល់ច្រឡំពីវា អ្នកឃើញទេ។ ពួកគេគ្រាន់តែបរិភោគអាហារ ឃើញទេ។ ដូចមនុស្សកំពុងធ្វើនៅសព្វថ្ងៃនេះដែរ គ្រាន់តែរស់នៅតាមប្រភេទណាក៏ដោយនៃជីវិតហើយធ្វើវាទៅ។ ឃើញទេ? ទ្រង់មានបន្ទូលថា "អ្នកទៅផ្ទះហើយញ៉ាំទៅ។ ប៉ុន្តែនេះគឺជាពិធីបរិសុទ្ធដែលយើងគួរតែរក្សា ឃើញទេ។" ឥឡូវនេះ

*ត្រូវឲ្យមនុស្សល្បងខ្លួនឯងមើល រួចសឹមបរិភោគនំបុ័ង ហើយផឹកពីពែងនេះចុះ*

*ដ្បិតអ្នកណាដែលបរិភោគបែបមិនគួរសម អ្នកនោះឈ្មោះថាបរិភោគជាសេចក្ដីជំនុំជំរះដល់ខ្លួនវិញ ដោយព្រោះមិនពិចារណាឃើញរូបអង្គនៃព្រះអម្ចាស់ទេ។* (ឃើញទេ?)

73 តើអ្នកជាអ្វី? អ្នកគឺជាគ្រីស្ទាន អ្នករស់នៅមុខមនុស្សគ្រប់គ្នាជាគ្រីស្ទាន។ ហើយបើសិនជាអ្នកទទួលវា ហើយមិនរស់នៅជាគ្រីស្ទាន អ្នកមិនយល់អំពីព្រះកាយរបស់ព្រះអម្ចាស់ទេ។ អ្នកកំពុងដាក់ប្លុកជំពប់ដួលនៅក្នុងផ្លូវរបស់អ្នកដទៃ ឃើញទេ នៅពេលដែលពួកគេឃើញអ្នកព្យាយាមធ្វើដូច្នេះ ហើយមិនរស់នៅអ្វីដែលអ្នកគួររស់នៅ។ ឃើញទេ អ្នកមិនយល់ពីព្រះកាយរបស់ព្រះអម្ចាស់ទេ។ ឥឡូវនេះមើលអ្វីដែល...អ្វីដែលបណ្ដាសារបស់វាគឺ:

*គឺដោយហេតុនោះបានជាមានអ្នករាល់គ្នាជាច្រើន ទៅជាខ្សោយ ហើយឈឺ ក៏មានគ្នាជាច្រើនដេកលក់ទៅហើយដែរ។* (ការបកប្រែដែលត្រឹមត្រូវសម្រាប់ពាក្យនេះ បងប្រុសភារី គឺ *"ស្លាប់" ឃើញទេ ឃើញទេ?* "មានគ្នាជាច្រើនបានស្លាប់។")

*បើសិន—បើសិនជាយើងរាល់គ្នាពិចារណាមើលក្នុងខ្លួនយើង នោះយើងមិនត្រូវជាប់ជំនុំជំរះទេ។* (ឃើញទេ? ប្រសិនបើអ្នករាល់គ្នាជំនុំជំរះខ្លួនឯងនោះយើងមិនត្រូវជាប់ជំនុំជំរះទេ។ ឃើញទេ?)

*តែកាលណាយើងរាល់គ្នាត្រូវជាប់ជំនុំជំរះ នោះព្រះអម្ចាស់ទ្រង់វាយផ្ចាលយើងវិញ ដើម្បីកុំឲ្យយើងជាប់ទោសជាមួយនឹងលោកីយ៍ឡើយ។ (ឃើញទេ កុំឲ្យយើងជាប់នឹងលោកីយ៍។)*

*ដូច្នេះ បងប្អូនអើយ កាលណាប្រជុំគ្នា ដើម្បីនឹងបរិភោគនោះត្រូវបង្អង់ចាំគ្នាផង។* (ឃើញទេ?)

*បើសិនជាអ្នកណាឃ្លាន ឲ្យអ្នកនោះបរិភោគនៅឯផ្ទះចុះ ដើម្បីកុំឲ្យអ្នករាល់គ្នាប្រជុំទៅ នាំឲ្យជាប់មានទោសឡើយ ឯការឯទៀត ដល់កាលណាខ្ញុំមក នោះខ្ញុំនឹងសំរេចគ្រប់ទាំងអស់។* (ឃើញទេ?)

74 ឥឡូវនេះនៅក្នុងពាក្យផ្សេងទៀត មិនមែនគ្រាន់តែចូលមក...ដូចដែលខ្ញុំបាននិយាយមុននេះបន្តិច អំពីអ្វីដែលសាសន៍យូដាថ្វាយការបូជារបស់ពួកគេ...វាជាការអស្ចារ្យ វាត្រូវបានផ្តល់ដោយព្រះ ប៉ុន្តែវាបានទៅដល់កន្លែងមួយ ដែលពួកគេមិនបានធ្វើវាដោយភាពស្មោះត្រង់និងការគោរព ហើយនៅក្នុងលំដាប់បន្ទាប់មកវាបានក្លាយជា...ជាក្លិនស្អុយនៅក្នុងច្រមុះរបស់ទ្រង់។

75 ឥឡូវនេះ រឿងដូចគ្នានេះដែរ ដែលយើងមកទទួលពិធីលៀងព្រះអម្ចាស់ ដែលយើងត្រូវតែដឹងពីអ្វីដែលយើងកំពុងតែធ្វើ។ ដូចជានៅពេលដែលលោកអ្នកចូលទៅក្នុងទឹកដើម្បីទទួលបុណ្យជ្រមុជទឹកនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ លោកអ្នកដឹងពីអ្វីដែលលោកអ្នកកំពុងធ្វើ ហើយលោកអ្នកកំពុងតែដាក់ទៅកាន់ពួកជំនុំនូវអ្វីដែលព្រះទ្រង់បានដាក់នៅក្នុងលោកអ្នកគឺជាព្រះគ្រីស្ទ។

76 នៅពេលដែលយើងទទួលយកវា វាបង្ហាញដល់ពួកជំនុំថា "ខ្ញុំបានជឿគ្រប់ទាំងព្រះបន្ទូលរបស់ព្រះ។ ខ្ញុំជឿថាទ្រង់ជានំបុ័ងជីវិតដែលមកពីព្រះវរបិតាពីស្ថានសួគ៌។ ខ្ញុំជឿថាព្រះបន្ទូលទាំងអស់ដែលទ្រង់មានបន្ទូលគឺជាសេចក្តីពិត។ ហើយខ្ញុំរស់នៅដោយសារវា គឺវាល្អបំផុតសម្រាប់ចំនេះដឹងរបស់ខ្ញុំ ថាព្រះជាចៅក្រមរបស់ខ្ញុំ។ ដូច្នេះនៅមុខបងប្អូនប្រុសរបស់ខ្ញុំ នៅចំពោះមុខបងប្អូនស្រីរបស់ខ្ញុំ...ខ្ញុំមិនស្បថ—ខ្ញុំមិនដាក់បណ្តាសាទេ ខ្ញុំមិនធ្វើរឿងទាំងនេះទេ ព្រោះ

ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ហើយព្រះអម្ចាស់ជ្រាប ហើយបានកត់ត្រាខ្ញុំ។ ដូច្នេះ នៅចំពោះមុខអ្នកខ្ញុំយកចំណិតនៃរាងកាយរបស់ទ្រង់ ដើម្បីដឹងថាខ្ញុំមិនត្រូវជាប់នឹងលោកិយទ្បើយ។ ឃើញទេ ហ្នឹងហើយ បន្ទាប់មកវាជាព្រះពរ។

77 ហើយ ចងចាំថា ខ្ញុំអាចផ្តល់ទីបន្ទាល់ជាច្រើនពីការនេះ ដែលជាកន្លែងដែលខ្ញុំបានយក ហើយបានពន្យល់វានៅក្នុងបន្ទប់អ្នកជំងឺ ណាហើយមើល ពួកគេបានជាសះស្បើយ។

78 សូមចាំថា នៅពេលដែលអ៊ីស្រាអែលបានយកប្រភេទនៃការនេះ ពួកគេបានធ្វើដំណើរអស់រយៈពេល ៤០ឆ្នាំនៅក្នុងទីរហោស្ថាន ហើយសម្លៀកបំពាក់របស់ពួកគេមិនដែលសឹកទេ ហើយពួកគេបានចេញមកដោយគ្មានអ្នកទន់ខ្សោយម្នាក់ណា—ក្នុងចំណោមពួកគេទ្បើយ ដោយមានមនុស្សពីរលាននាក់ជាក្នុងនៃរឿងនេះ។ មែនហើយ តើពួកគេធ្វើអ្វី? ប្រសិនរាងកាយរបស់តង្វាយយញ្ញបូជាបានធ្វើសម្រាប់ពួកគេ នោះតើអ្វីទៅជាតួនៃព្រះយេស៊ូវគ្រីស្ទ អេម៉ាញូអែល ធ្វើសម្រាប់យើង? ចូរយើងគោរពនៅពេលយើងមកដល់។ សូមឲ្យយើងមានភាពគោរពដូចដែលយើងដឹងពីរបៀបដែលត្រូវទទួល។

**ការប្រកបរួបរួមគ្នា** KHM65-1212

(Communion)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅល្ងាចថ្ងៃអាទិត្យ ថ្ងៃទី12 ធ្នូ 1965 នៅ រោងឧបោសថ Tucson, Tucson, Arizona, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថត ចម្លង និង បោះពុម្ព ដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបកប្រែជាភាសារខ្មែរ នេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយសម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2019 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG